- បានឃើញអនុក្រឹត្យលេខ ២៥៩ អនក្រ.បក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការគ្រប់គ្រងថវិកា គណនេយ្យ និងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ
- បានឃើញអនុក្រឹត្យលេខ២៨៩អនក្រ.បកចុះថ្ងៃទី២០ខែកញ្ញា ឆ្នាំ២០២៣ស្ដីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្ដីពីការដាក់ឲ្យអនុវត្តមាតិកាគណនី នៃប្លង់គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការដាក់ឲ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិកាបេស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ០១៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៨ ស្ដីពីការឲ្យអនុវត្តគោលការណ៍ណែនាំស្ដីកិច្ច បញ្ជិកាគណនេយ្យទូទៅគណនេយ្យរដ្ឋទេយ្យបុរេប្រទាននិងគណនេយ្យរដ្ឋទេយ្យចំណូលរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ១៣៩៦ សហវ.ប្រក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្ដីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទាន សម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ពហុកីឡដ្ឋានជាតិនៃក្រសួងអប់រំ យុវជន និងកីឡា។

សម្រេច

ប្រការ១ .-

ត្រូវបានតែងតាំង គណនេយ្យករនិងជំនួយការគណនេយ្យប្រចាំពហុកីឡដ្ឋានជាតិដូចមានរាយនាមខាងក្រោម៖

១- លោក **ឈាន សុខឃាង** ជាគណនេយ្យករប្រចាំ**ពហុកីឡដ្ឋានជាតិ** បន្ថែមលើមុខងារបច្ចុប្បន្ន

២- កញ្ញា **តេង សុផាន់ណែត** ជាជំនួយការគណនេយ្យប្រចាំ**ពហុកីឡដ្ឋានជាតិ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

ប្រការ២ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៣ .-

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋានពាក់ព័ន្ធ អគ្គាធិការនៃអគ្គាធិការដ្ឋាន និង ពហុកីឡដ្ឋានជាតិ ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចមានចែង ក្នុងប្រការ១ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ ១៣រោច ខែ មិគសិរ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ២០២៤

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៥៦ សហវ.ប្រក

ប្រកាស
ស្តីពី
ការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំ ស្តីពីការតាមដាន និងវាយតម្លៃថវិកាសមិទ្ធកម្ម បច្ចុប្បន្នកម្ម ឆ្នាំ២០២៥

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលមាត្រា៥០ មាត្រា៥១ មាត្រា៥២ និងមាត្រា៥៣ នៃអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០៦៨ សហវ.ប្រក ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៤ ស្តីពីការដាក់អនុវត្តថវិកាកម្មវិធីពេញលេញ
- បានឃើញប្រកាសលេខ ២៣៧ សហវ.ប្រក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធី
- បានឃើញប្រកាសលេខ ២៨៧ សហវ.ប្រក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការរៀបចំថវិកាសមិទ្ធកម្ម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia

ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

សម្រេច

ប្រការ១.-

ដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការតាមដាន និងវាយតម្លៃថវិកាសមិទ្ធកម្ម បច្ចុប្បន្នកម្ម ឆ្នាំ២០២៥ ដូចមានខ្លឹមសារភ្ជាប់មកជាមួយប្រកាសនេះ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រក្សាសិទ្ធិក្នុងការធ្វើបច្ចុប្បន្នភាព និងកែតម្រូវគោលការណ៍ណែនាំនេះ តាមការចាំបាច់ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តនូវការតាមដាន និងវាយតម្លៃថវិកាសមិទ្ធកម្ម។

ប្រការ២.-

ប្រកាសលេខ ១១៣ សហវ. ប្រក ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការតាមដាន និងវាយតម្លៃថវិកាសមិទ្ធកម្ម និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៣.-

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមការកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៨រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ ២០២៥

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

កន្លែងទទួល៖

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ [illegible] សហវ.[illegible]

ប្រកាស
ស្ដីពី
ការដាក់ឱ្យអនុវត្តយន្តការប្រមូលកម្រៃសេវារដ្ឋបាល សម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពី ការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពី ការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពី ការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២១/០១៨ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីគណនេយ្យ និងសវនកម្ម

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia

ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧៤ អនក្រ.បក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ ស្តីពីការដាក់ឱ្យប្រើនីតិវិធីគ្រប់គ្រងប្រតិបត្តិការរួមសម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

ប្រការ១.-

ប្រកាសនេះ មានគោលបំណងដាក់ឱ្យអនុវត្តយន្តការប្រមូលកម្រៃសេវារដ្ឋបាលពីដៃគូឯកជន សម្រាប់គាំទ្រកិច្ចការផ្នែករដ្ឋបាលពាក់ព័ន្ធការអនុវត្តរៀបចំគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន (ភ.រ.ឯ.) និងធានានូវនិរន្តរភាពនៃមូលនិធិអភិវឌ្ឍន៍គម្រោង ភ.រ.ឯ. អនុលោមតាមមាត្រា១២ នៃច្បាប់ស្តីពី ភ.រ.ឯ. និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

ប្រការ២.-

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះរាល់គម្រោង ភ.រ.ឯ. ដោយពុំរាប់បញ្ចូលនូវគម្រោងដែលបានបញ្ចប់កិច្ចលទ្ធកម្ម ឬបានចុះកិច្ចព្រមព្រៀងក្របខណ្ឌ និងគម្រោងដែលបានចុះកិច្ចសន្យា ភ.រ.ឯ.។

ប្រការ៣.-

អត្រាកម្រៃសេវារដ្ឋបាលពីដៃគូឯកជន នឹងត្រូវកំណត់ដូចខាងក្រោម៖

ក. សំណើគម្រោងផ្តួចផ្តើមដោយរដ្ឋ៖ ចំនួន ២ (ពីរ) ភាគរយ នៃទំហំថវិកាចំណាយជាក់ស្តែងលើការរៀបចំអភិវឌ្ឍគម្រោង ដែលបានវិភាជពីមូលនិធិអភិវឌ្ឍន៍គម្រោង ភ.រ.ឯ.។

ខ. សំណើគម្រោងផ្តួចផ្តើមដោយឯកជន៖ ចំនួន ២ (ពីរ) ភាគរយ នៃទំហំថវិកាចំណាយជាក់ស្តែងលើការរៀបចំអភិវឌ្ឍគម្រោង ក្នុងករណីដែលប្រើប្រាស់ថវិកាបុរេប្រទានរបស់ខ្លួន ឬចំនួន ៥ (ប្រាំ) ភាគរយ នៃទំហំថវិកាចំណាយជាក់ស្តែងលើការរៀបចំអភិវឌ្ឍគម្រោង ដែលបានវិភាជពីមូលនិធិអភិវឌ្ឍន៍គម្រោង ភ.រ.ឯ.។

អត្រាកម្រៃសេវារដ្ឋបាលនេះ អាចមានការកែសម្រួលតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ប្រការ៤.-

កម្រៃសេវារដ្ឋបាលពីដៃគូឯកជន ដូចមានកំណត់នៅក្នុងប្រការ៣ ខាងលើ ត្រូវបង់ចូលទៅក្នុងគណនីមូលនិធិអភិវឌ្ឍន៍គម្រោង ភ.រ.ឯ. ដោយកាតព្វកិច្ចនេះត្រូវបញ្ជាក់ច្បាស់លាស់នៅក្នុងឯកសារដេញថ្លៃ ចំពោះសំណើគម្រោងផ្តួចផ្តើមដោយរដ្ឋ ឬកិច្ចព្រមព្រៀងក្របខណ្ឌ ចំពោះសំណើគម្រោងផ្តួចផ្តើមដោយឯកជន។

ប្រការ៥.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៦.-

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋនិងឯកជន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែ មាឃ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ គ.ស. ២០២៥

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៦ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.០៥៦......សហវ.ប្រក.

ប្រកាស
ស្តីពី
វិធាននិងនីតិវិធីសវនកម្មចំពោះបរធនបាលកិច្ច

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសវនកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០២ ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីបរធនបាលកិច្ច
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia

ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

សម្រេច

ប្រការ១ .-

ប្រកាសនេះ មានគោលបំណងកំណត់អំពីវិធាននិងនីតិវិធីសារពើពន្ធចំពោះប្រតិបត្តិការបរធនបាលកិច្ច។

ប្រការ២ .-

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះបរធនបាលទាយក បរធនបាល និងអត្ថគាហកៈ ជាអ្នកជាប់ពន្ធនិវាសនជនឬជាអ្នកជាប់ពន្ធអនិវាសនជនដែលធ្វើប្រតិបត្តិការពាក់ព័ន្ធនឹងបរធនបាលកិច្ចដែលបានបង្កើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា វៀរលែងតែបរធនបាលកិច្ចមានទម្រង់គតិយុត្តជាក្រុមហ៊ុនឬសហគ្រាស។

ប្រការ៣ .-

សម្រាប់គោលដៅនៃប្រកាសនេះ៖

១- ក្រុមហ៊ុនបរធនបាល សំដៅដល់ បរធនបាលជានីតិបុគ្គលដែលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតពីនិយ័តករបរធនបាលកិច្ចឱ្យធ្វើប្រតិបត្តិការបរធនបាលកិច្ចមួយឬច្រើន។

២- ទ្រព្យសម្បត្តិបរធនបាលកិច្ច សំដៅដល់ ទ្រព្យសម្បត្តិឬមូលនិធិដែលបានផ្ទេរទៅក្នុងបរធនបាលកិច្ច និងផលដែលបានពីទ្រព្យសម្បត្តិឬមូលនិធិនោះ។

៣- បរធន សំដៅដល់ ទ្រព្យសម្បត្តិឬមូលនិធិដែលបានផ្ទេរទៅឱ្យបរធនបាលគ្រប់គ្រង និងចាត់ចែងសម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ តាមលក្ខខណ្ឌដែលកំណត់ដោយលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

៤- បរធនបាល សំដៅដល់ ក្រុមហ៊ុនបរធនបាលឬបរធនបាលជារូបវន្តបុគ្គលដែលទទួលសិទ្ធិគ្រប់គ្រង ចាត់ចែងនិងថែរក្សាបរធនពីបរធនបាលទាយកឬអ្នកផ្ដល់វិភាគទានបរធនបាលកិច្ចសម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ ដោយអនុលោមតាមលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

៥- បរធនបាលកិច្ច សំដៅដល់ កិច្ចការគ្រប់គ្រង និងចាត់ចែងបរធន ដែលផ្ដល់ដោយបរធនបាលទាយកសម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ ដោយអនុលោមតាមលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

៦- បរធនបាលទាយក សំដៅដល់ បុគ្គលដែលបង្កើតនិងកំណត់លក្ខខណ្ឌនៃបរធនបាលកិច្ច និងផ្ដល់ទ្រព្យសម្បត្តិឬមូលនិធិដំបូងនៅក្នុងបរធនបាលកិច្ច។

៧- បរធនបាលរូបវន្តបុគ្គលឯករាជ្យ សំដៅដល់ រូបវន្តបុគ្គលដែលទទួលបានអាជ្ញាបណ្ណពីនិយ័តករបរធនបាលកិច្ចឱ្យធ្វើប្រតិបត្តិការបរធនបាលកិច្ចមួយឬច្រើន ហើយបរធនបាលរូបវន្តបុគ្គលឯករាជ្យនេះ មិនស្ថិតនៅក្រោមលក្ខខណ្ឌអាជ្ញាបណ្ណរបស់ក្រុមហ៊ុនបរធនបាលណាមួយឡើយ។

៨- ប្រតិបត្តិការបរធនបាលកិច្ច សំដៅដល់ ការធ្វើប្រតិបត្តិការបរធនបាលកិច្ចដោយបរធនបាល ឬអ្នកចូលរួមដទៃទៀតទៅតាមប្រភេទបរធនបាលកិច្ច រួមមាន បរធនបាលកិច្ចសាធារណៈ បរធនបាលកិច្ចហិរញ្ញវត្ថុ បរធនបាលកិច្ចពាណិជ្ជកម្ម បរធនបាលកិច្ចសង្គម និងបរធនបាលកិច្ចបុគ្គល។ បរធនបាល ឬអ្នកចូលរួមដទៃទៀតដែលអាចធ្វើប្រតិបត្តិការបរធនបាលកិច្ចទាំងនេះ ត្រូវទទួលបានអាជ្ញាបណ្ណឬការអនុញ្ញាតឬការចុះបញ្ជីពីនិយ័តករបរធនបាលកិច្ច។

៩- លិខិតបរធនបាលកិច្ច សំដៅដល់៖

ក- លិខិតគតិយុត្តដែលកំណត់ជាអាទិ៍អំពីការបង្កើត ការគ្រប់គ្រង ការចាត់ចែង និងការបញ្ចប់បរធនបាលកិច្ច ដែលត្រូវបានធ្វើឡើងរវាងបរធនបាលទាយកឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច និងបរធនបាលដោយមានការបញ្ជាក់ពីសារការីឬមេឃុំ/ចៅសង្កាត់ឬដោយបុគ្គលផ្សេងទៀតដែលមានចែងក្នុងបទប្បញ្ញត្តិជាធរមាន។

ខ- មតកសាសន៍ដែលធ្វើឡើងស្របតាមបទប្បញ្ញត្តិស្តីពីសន្តតិកម្មនៃក្រមរដ្ឋប្បវេណី។

១០-សេវារក្សាទុក សំដៅដល់ ការផ្ទេរទ្រព្យសម្បត្តិឬមូលនិធិដោយបុគ្គលណាមួយ ទៅឱ្យបរធនបាលដើម្បីរក្សាទុក ហើយប្រគល់ទៅឱ្យបុគ្គលផ្សេងទៀតឬប្រគល់ត្រឡប់ទៅឱ្យបុគ្គលនោះវិញ តាមលក្ខខណ្ឌដែលបានកំណត់នៅក្នុងលិខិតបរធនបាលកិច្ច។

១១-អត្ថគាហកៈ សំដៅដល់ បុគ្គលដែលទទួលផលប្រយោជន៍ពីបរធនបាលកិច្ច។

១២-អ្នកផ្តល់វិភាគទានបរធនបាលកិច្ច សំដៅដល់ បុគ្គលដែលផ្តល់វិភាគទាននៅក្នុងបរធនបាលកិច្ច ឬបរធនបាលកិច្ចដែលមានស្រាប់ និងមានសិទ្ធិចូលរួមកំណត់លក្ខខណ្ឌនៃការបង់វិភាគទានដែលនឹងត្រូវគ្រប់គ្រង និងចាត់ចែងដោយបរធនបាល និងលក្ខខណ្ឌនៃការទទួលផលរបស់អត្ថគាហកៈ។

ប្រការ៤ .-

ប្រភេទបរធនបាលកិច្ចចម្បងៗ មានដូចខាងក្រោម៖

១- បរធនបាលកិច្ចសាធារណៈ ត្រូវបានបង្កើតឡើងក្នុងគោលបំណងជាប្រយោជន៍របស់ប្រជាពលរដ្ឋខ្មែរទូទៅ។ បរធនបាលកិច្ចនេះ រួមមាន៖

ក- ការអភិវឌ្ឍវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុនៅកម្ពុជា នៅពេលដែល៖

- ដៃគូអភិវឌ្ឍន៍ផ្តល់ទ្រព្យសម្បត្តិ ឬមូលនិធិរបស់ខ្លួនសម្រាប់ជាប្រយោជន៍របស់ប្រជាពលរដ្ឋខ្មែរ ហើយទ្រព្យសម្បត្តិ ឬមូលនិធិទាំងនោះបាននិងកំពុងគ្រប់គ្រងនិងចាត់ចែងនៅក្នុងគ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ ឬបុគ្គលផ្សេងទៀត និង
- តាមលក្ខខណ្ឌដែលមានកំណត់នៅក្នុងលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

ខ- ជាប្រយោជន៍សាធារណៈផ្សេងទៀតនៅពេលដែលបញ្ញត្តិករពាក់ព័ន្ធតែងតាំងបរធនបាលដើម្បីគ្រប់គ្រង និងការពារមូលនិធិនានាតាមលក្ខខណ្ឌដែលកំណត់ដោយលិខិតបរធនបាលកិច្ច ឬបទប្បញ្ញត្តិជាធរមាន។ លក្ខខណ្ឌទាំងនេះមានជាអាទិ៍៖

- មូលនិធិដែលបានផ្តល់ឱ្យរាជរដ្ឋាភិបាល ឬត្រូវបានផ្តល់ដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីបំពេញគោលបំណងជាក់លាក់ណាមួយរបស់អ្នកផ្តល់ជំនួយ ហើយអ្នកផ្តល់ជំនួយទាមទារឱ្យមូលនិធិនេះ ត្រូវបានចាត់ចែងប្រើប្រាស់និងអាស្រ័យផលស្របតាមគោលបំណងរបស់ខ្លួន ឬ
- ត្រូវការពារផលប្រយោជន៍របស់កុមារឬអសមត្ថជនផ្សេងទៀត ឬ
- មត៌កដែលធ្លាក់ទៅជាទ្រព្យរដ្ឋតាមបទប្បញ្ញត្តិជាធរមាន។

២- បរធនបាលកិច្ចពាណិជ្ជកម្ម ត្រូវបានបង្កើតឡើងក្នុងគោលបំណងស្វែងរកប្រាក់ចំណេញ សម្រាប់ជាប្រយោជន៍ដល់អ្នកផ្តល់វិភាគទានបរធនបាលកិច្ច ឬបុគ្គលណាមួយជាក់លាក់ដែលកំណត់ដោយអ្នកផ្តល់វិភាគទានបរធនបាលកិច្ច រួមមាន៖

ក- មូលនិធិសោធននិវត្តន៍ មូលនិធិអប់រំ និងមូលនិធិប្រហាក់ប្រហែលផ្សេងទៀតដែលបុគ្គលណាមួយផ្ទេរទ្រព្យសម្បត្តិឱ្យបរធនបាល ហើយត្រូវបានផ្ទេរត្រឡប់ទៅឱ្យបុគ្គលនោះវិញឬផ្ទេរឱ្យបុគ្គលណាមួយផ្សេងទៀតនៅពេលដែលបានបំពេញតាមលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

- មានការផ្ទេរទ្រព្យសម្បត្តិ ឬមូលនិធិទៅក្នុងបរធនបាលកិច្ចដោយបុគ្គលណាម្នាក់ឱ្យទៅបរធនបាលជាប្រចាំ ហើយបរធនបាលគ្រប់គ្រងនិងចាត់ចែងមូលនិធិនេះសម្រាប់ជាប្រយោជន៍ជាក់លាក់របស់បុគ្គលនេះឬបុគ្គលផ្សេងទៀត ហើយ
- នៅពេលដែលទ្រព្យសម្បត្តិ ឬមូលនិធិរបស់អ្នកផ្ដល់វិភាគទានផ្សេងទៀត ត្រូវបានដាក់បញ្ចូលក្នុងគម្រោងវិនិយោគ ហើយត្រូវបានវិនិយោគដោយបរធនបាលសម្រាប់ជាប្រយោជន៍របស់អ្នកផ្ដល់វិភាគទានទាំងអស់តាមលក្ខខណ្ឌដែលបានកំណត់ និង
- នៅពេលដែលទ្រព្យសម្បត្តិ និងផលដែលបានមកពីការវិនិយោគត្រូវបានកំណត់ គ្រប់គ្រង និងរាយការណ៍ដាច់ដោយឡែកទៅបុគ្គលនោះ។

ខ- សេវារក្សាទុកដែលក្នុងនោះមានការផ្ទេរទ្រព្យសម្បត្តិឬមូលនិធិដោយបុគ្គលណាមួយឱ្យទៅបរធនបាល ហើយបរធនបាលត្រូវផ្ទេរត្រឡប់ឱ្យទៅបុគ្គលនេះវិញ ឬឱ្យទៅបុគ្គលណាមួយផ្សេងទៀតនៅពេលដែលបានបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

- មានការរក្សាទុកទ្រព្យសម្បត្តិឬមូលនិធិដោយបុគ្គលណាមួយ មានជាអាទិ៍ មន្ទីរសារការី ឬការិយាល័យមេធាវី ឬក្រុមហ៊ុនគណនេយ្យ ឬ
- មានការកាន់កាប់ទ្រព្យសម្បត្តិឬមូលនិធិតម្កល់ដើម្បីជាប្រយោជន៍របស់វិនិយោគិន អ្នកទិញអចលនវត្ថុ និងដើម្បីប្រតិបត្តិការពាណិជ្ជកម្មផ្សេងៗទៀត ឬ
- សេវារក្សាទុកផ្សេងទៀតដែលទទួលបានការអនុញ្ញាតតាមសេចក្ដីសម្រេចរបស់បញ្ញត្តិករផ្សេងទៀត មានជាអាទិ៍ ធនាគារជាតិនៃកម្ពុជា និយ័តករមូលបត្រកម្ពុជា ឬក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីគ្រប់គ្រងសកម្មភាពនានាដែលស្ថិតក្រោមតួនាទីនិងភារកិច្ចរបស់ខ្លួន។

គ- គម្រោងភាគហ៊ុននិយោជិតឬផលប្រយោជន៍និយោជិត នៅពេលដែលបរធនបាលគ្រប់គ្រងទ្រព្យសម្បត្តិ ឬមូលនិធិ ដើម្បីវិនិយោគក្នុងនាមនិយោជិតនោះ និង

ឃ- ដើម្បីគោលបំណងផ្សេងទៀត៖

- នៅពេលដែលមានការផ្ទេរទ្រព្យសម្បត្តិ ឬមូលនិធិដោយបុគ្គលណាមួយឱ្យទៅបរធនបាលសម្រាប់ជាប្រយោជន៍ដល់អ្នកផ្ដល់វិភាគទានឬបុគ្គលផ្សេងទៀតដែលកំណត់ដោយអ្នកផ្ដល់វិភាគទាន និង
- នៅពេលដែលបទប្បញ្ញត្តិជាធរមាន ចែងអំពីវិធានស្ដីពីដំណើរការនិងការគ្រប់គ្រងសកម្មភាពនៃបរធនបាលកិច្ច។

៣- បរធនបាលកិច្ចសង្គម ត្រូវបានបង្កើតឡើងនៅពេលដែលបរធនបាលទាយកធ្វើប្រទានកម្មទ្រព្យសម្បត្តិរបស់ខ្លួនឱ្យទៅបរធនបាល ដើម្បីប្រើប្រាស់ជាប្រយោជន៍ទូទៅក្នុងសង្គម ដូចជាក្នុងគោលបំណងវប្បធម៌ អប់រំ មនុស្សជាតិ សាសនា ឬវិទ្យាសាស្ត្រ។ បរធនបាលកិច្ចសង្គម រួមមាន៖

ក- មូលនិធិពិសេស៖

- មូលនិធិដែលបង្កើតដោយបរធនបាលទាយកតាមរយៈប្រទានកម្ម ឬមតកសាសន៍

- តាមរយៈការទទួលទ្រព្យសម្បត្តិពីអ្នកផ្តល់វិភាគទានបរធនបាលកិច្ចនៅមានជីវិតឬទទួលទ្រព្យសម្បត្តិតាមមតកសាសន៍របស់អ្នកផ្តល់វិភាគទានបរធនបាលកិច្ច និង
- ទ្រព្យសម្បត្តិត្រូវបានផ្ទេរឱ្យទៅបរធនបាល ដើម្បីបំពេញគោលបំណងជាប្រយោជន៍សង្គម និង
- មិនស្វែងរកប្រាក់ចំណេញឬគ្មានប្រតិបត្តិការជាសហគ្រាសពាណិជ្ជកម្ម និង
- លើកលែងតែមានចែងផ្សេងក្នុងលិខិតបរធនបាលកិច្ច ទ្រព្យសម្បត្តិដំបូងនិងទ្រព្យសម្បត្តិបន្ថែមផ្សេងទៀត ដែលអ្នកផ្តល់វិភាគទានបរធនបាលកិច្ចបានផ្ទេរចូលមូលនិធិណាមួយ ត្រូវរក្សាទុកដើម្បីបំពេញគោលបំណងបរធនបាលកិច្ច ហើយអនុញ្ញាតឱ្យចែកចាយតែផលដែលបានពីទ្រព្យសម្បត្តិនោះប៉ុណ្ណោះ។

ខ- មូលនិធិសម្រាប់ជាប្រយោជន៍ដល់អង្គការវប្បធម៌ អប់រំ មនុស្សជាតិ សាសនា ឬវិទ្យាសាស្ត្រ៖ ទ្រព្យសម្បត្តិទទួលពីបុគ្គល រួមមានប្រទានកម្ម ឬមតកសាសន៍ ហើយទ្រព្យសម្បត្តិនេះត្រូវបានផ្ទេរដើម្បីបម្រើគោលដៅសម្រាប់ជាប្រយោជន៍ ជាអាទិ៍ វប្បធម៌ អប់រំ មនុស្សជាតិ សាសនា ឬវិទ្យាសាស្ត្រ។

៤- បរធនបាលកិច្ចបុគ្គលត្រូវបានបង្កើតឡើងសម្រាប់ជាប្រយោជន៍របស់បរធនបាលទាយក ឬបុគ្គលដែលកំណត់ជាក់លាក់ដោយបរធនបាលទាយកតាមលក្ខខណ្ឌដូចខាងក្រោម៖

ក- បរធនបាលទាយកជារូបវន្តបុគ្គលដែលធ្វើប្រទានកម្មទ្រព្យសម្បត្តិឬមូលនិធិរបស់ខ្លួនឱ្យទៅបរធនបាលសម្រាប់ជាប្រយោជន៍របស់ខ្លួនផ្ទាល់ឬរបស់បុគ្គលផ្សេងទៀត ឬ

ខ- ការផ្ទេរទ្រព្យសម្បត្តិឬមូលនិធិ ដោយបរធនបាលទាយក៖

- ករណីបរធនបាលទាយកនៅមានជីវិត បរធនបាលទាយកនោះត្រូវធ្វើលិខិតបរធនបាលកិច្ចដោយមានការបញ្ជាក់ពីសារការី ឬមេធាវី ឬឃុំ/សង្កាត់ ឬដោយបុគ្គលផ្សេងទៀតដែលមានចែងក្នុងបទប្បញ្ញត្តិជាធរមាន
- ករណីបរធនបាលទាយកធ្វើមតកសាសន៍ នៅពេលដែលបរធនបាលទាយកនោះទទួលមរណភាព តាមរយៈមតកសាសន៍នេះ បង្កើតជាបរធនបាលកិច្ចដែលស្របតាមបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

ប្រការ៥ .-

ក្រុមហ៊ុនបរធនបាលត្រូវចុះបញ្ជីពន្ធដារជាអ្នកជាប់ពន្ធមធ្យមឬអ្នកជាប់ពន្ធធំ។ ដោយឡែក បរធនបាលរូបវន្តបុគ្គលឯកជន ត្រូវចុះបញ្ជីពន្ធដារជាអ្នកជាប់ពន្ធតូច ឬអ្នកជាប់ពន្ធមធ្យម ឬអ្នកជាប់ពន្ធធំ ដោយផ្អែកលើកម្រិតផលរបរឬទ្រព្យសកម្មអាជីវកម្ម ដូចមានចែងក្នុងប្រកាសស្តីពីការកំណត់ចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ក្នុងអំឡុងពេល ១៥ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច ឬក្រោយពីពេលទទួលបានអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតពីនិយ័តករបរធនបាលកិច្ច។

ប្រការ៦ .-

បរធនបាលត្រូវមានកាតព្វកិច្ចកាន់បញ្ជិកាគណនេយ្យដូចខាងក្រោម៖

១- ត្រូវកត់ត្រាដាច់ដោយឡែកពីគ្នារវាងបញ្ជិកាគណនេយ្យរបស់បរធនបាលនិងប្រតិបត្តិការបរធនបាលកិច្ច។ បរធនបាលត្រូវកំណត់ឱ្យបានច្បាស់លាស់នូវកម្មសិទ្ធិលើទ្រព្យសម្បត្តិ ចំណូល ចំណាយ បំណុល និងប្រតិបត្តិការផ្សេងៗសម្រាប់កត់ត្រាក្នុងបញ្ជិកាគណនេយ្យរបស់ខ្លួនឯង និងបញ្ជិកាគណនេយ្យរបស់ប្រតិបត្តិការបរធនបាលកិច្ច ដោយស្របតាមការកំណត់ក្នុងលិខិតបរធនបាលកិច្ច។

k

២- ត្រូវប្រើវិធានគណនេយ្យដូចមានចែងក្នុងមាត្រា៦ នៃច្បាប់ស្តីពីសារពើពន្ធ។

៣- ត្រូវរៀបចំបញ្ជីគណនេយ្យសម្រាប់ប្រតិបត្តិការបរធនបាលកិច្ចនីមួយៗដាច់ដោយឡែកពីគ្នា ក្នុងករណីបរធនបាលគ្រប់គ្រងប្រតិបត្តិការបរធនបាលកិច្ចលើសពីមួយ។

ប្រការ៧ .-

១- ប្រាក់ចំណូលជាប់ពន្ធ៖

ក- បរធនបាល ត្រូវជាប់ពន្ធលើប្រាក់ចំណូលចំពោះលាភការ ឬកម្រៃនានាដែលទទួលបានពីការគ្រប់គ្រងប្រតិបត្តិការបរធនបាលកិច្ច។ បរធនបាលត្រូវកត់ត្រាចំណូលទាំងនេះ និងកាត់កងជាមួយចំណាយពាក់ព័ន្ធនឹងប្រតិបត្តិការរបស់បរធនបាលក្នុងការគ្រប់គ្រងប្រតិបត្តិការបរធនបាលកិច្ច ស្របតាមវិធានទូទៅស្តីពីចំណាយដូចមានចែងក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធលើប្រាក់ចំណូលជាធរមាន។

ឧទាហរណ៍ទី១៖

បរធនបាលទាយក បានប្រគល់អគារមួយកន្លែងទៅឱ្យក្រុមហ៊ុនបរធនបាលដើម្បីគ្រប់គ្រងនិងចាត់ចែង។ ក្រុមហ៊ុនបរធនបាល បានយកអគារនេះដាក់ជួលទៅឱ្យបុគ្គលផ្សេងទៀតដោយទទួលបានចំណូលពីការជួលសរុបចំនួន ២០ លានរៀល ក្នុងមួយខែ ហើយក្រុមហ៊ុនបរធនបាលទទួលបានកម្រៃជើងសាចំនួន ១ លានរៀល (៥% នៃតម្លៃឈ្នួល) ក្នុងមួយខែស្របតាមលិខិតបរធនបាលកិច្ច។

ករណីនេះ ប្រាក់កម្រៃសេវាចំនួន ១ លានរៀល ត្រូវចាត់ទុកជាប្រាក់ចំណូលជាប់ពន្ធរបស់ក្រុមហ៊ុនបរធនបាល។

ខ- បរធនជាទ្រព្យសម្បត្តិឬមូលនិធិដែលបរធនបាលទាយកបានផ្ទេរទៅឱ្យបរធនបាលចាត់ចែងគ្រប់គ្រង និងថែរក្សា តាមលក្ខខណ្ឌដែលកំណត់ដោយលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន គឺពុំចាត់ទុកជាប្រាក់ចំណូលនិង/ឬទ្រព្យសម្បត្តិរបស់បរធនបាលទេ។

ឧទាហរណ៍ទី២៖

បរធនបាលទាយក បានផ្ទេរប្រាក់ទៅឱ្យក្រុមហ៊ុនបរធនបាលចំនួន ៣០០ លានរៀល ដើម្បីទិញដីមួយកន្លែង។

ករណីនេះ ប្រាក់ចំនួន ៣០០ លានរៀល ពុំត្រូវបានចាត់ទុកជាប្រាក់ចំណូលជាប់ពន្ធរបស់ក្រុមហ៊ុនបរធនបាលទេ។

២- អត្រាពន្ធ៖

បរធនបាលត្រូវអនុវត្តអត្រាពន្ធលើប្រាក់ចំណូលដូចមានចែងនៅក្នុងមាត្រា២០ នៃច្បាប់ស្តីពីសារពើពន្ធដូចខាងក្រោម៖

ក- ២០ (ម្ភៃ) ភាគរយ ចំពោះប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានដោយនីតិបុគ្គល។

ខ- ជាប់ពន្ធតាមអត្រាកំណើនតាមថ្នាក់ពី ០ (សូន្យ) ភាគរយ ដល់ ២០ (ម្ភៃ) ភាគរយ ចំពោះប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានដោយរូបវន្តបុគ្គល សហគ្រាសឯកបុគ្គល និងចំណែកដែលត្រូវបែងចែកឱ្យសមាជិកម្នាក់ៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធិ។

ប្រការ៨ .-

ទ្រព្យសម្បត្តិបរធនបាលកិច្ច ត្រូវជាប់ពន្ធស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារមានជាអាទិ៍៖

១- ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ៖

ចំណូលពីការជួលអចលនទ្រព្យដែលជាទ្រព្យសម្បត្តិបរធនបាលកិច្ច ត្រូវស្ថិតក្រោមវិសាលភាពនៃពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ។ បរធនបាលត្រូវមានកាតព្វកិច្ចកត់ត្រាចំណូលពីការជួលនោះ ដោយត្រូវគណនាពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ និងត្រូវដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធជូនរដ្ឋបាលសារពើពន្ធ ស្របតាមបទប្បញ្ញត្តិស្តីពីពន្ធលើថ្លៃឈ្នួលអចលនទ្រព្យជាធរមាន។

២- ពន្ធលើចំណេញមូលធន៖

ក្នុងករណីមានការលក់ឬផ្ទេរមូលធន ចំណូលពីការលក់ឬផ្ទេរទាំងនោះត្រូវស្ថិតក្រោមវិសាលភាពនៃពន្ធលើចំណេញមូលធន។ បរធនបាលជាអ្នកគ្រប់គ្រង និងចាត់ចែងបរធនបាលកិច្ចត្រូវមានកាតព្វកិច្ចកត់ត្រាចំណូលនៃប្រតិបត្តិការនោះ ដោយត្រូវគណនាពន្ធលើចំណេញមូលធន និងត្រូវដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធជូនរដ្ឋបាលសារពើពន្ធ ស្របតាមបទប្បញ្ញត្តិស្តីពីពន្ធលើចំណេញមូលធនជាធរមាន។

ឧទាហរណ៍ទី៣៖

បរធនបាលទាយក បានប្រគល់ប្រាក់ទៅឱ្យក្រុមហ៊ុនបរធនបាលចំនួន ៤០០ លានរៀល ដើម្បីទិញផ្ទះមួយកន្លែងដោយដាក់ឈ្មោះក្រុមហ៊ុនបរធនបាលជាកម្មសិទ្ធិករ ឬអ្នកកាន់កាប់អចលនទ្រព្យ។ ក្រោយមកក្រុមហ៊ុនបរធនបាល បានលក់ផ្ទះនេះក្នុងតម្លៃ ៦០០ លានរៀល។ ក្រុមហ៊ុនបរធនបាល បានជ្រើសរើសយកវិធីកាត់កងចំណាយតាមការកំណត់ ដែលត្រូវបានគណនាដូចខាងក្រោម៖

ចំណូលពីការលក់ផ្ទះ	= ៦០០ លានរៀល
ការកាត់កងចំណាយតាមការកំណត់	= ៨០% x ចំណូលពីការលក់ផ្ទះ
	= ៨០% x ៦០០ លានរៀល
	= ៤៨០ លានរៀល
ចំណេញមូលធន	= ចំណូលពីការលក់ផ្ទះ - ចំណាយតាមការកំណត់
	= ៦០០ លានរៀល - ៤៨០ លានរៀល
	= ១២០ លានរៀល
ពន្ធលើចំណេញមូលធន	= ចំណេញមូលធន x អត្រាពន្ធ
	= ១២០ លានរៀល x ២០%
	= ២៤ លានរៀល។

៣- ពន្ធប្រថាប់ត្រា៖

ក្នុងករណី មានការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់ ឬការដាក់ភាគហ៊ុនជាអចលនទ្រព្យនិងចលនទ្រព្យឬទ្រព្យសម្បត្តិបរធន ឬការផ្ទេរភាគហ៊ុន ការផ្ទេរទាំងនោះត្រូវស្ថិតក្រោមវិសាលភាពនៃពន្ធប្រថាប់ត្រា។ បរធនបាលជាអ្នកគ្រប់គ្រង និងចាត់ចែងបរធនបាលកិច្ច ត្រូវមានកាតព្វកិច្ចកត់ត្រាចំណូលពីប្រតិបត្តិការនោះ និងត្រូវដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធជូនរដ្ឋបាលសារពើពន្ធ ស្របតាមបទប្បញ្ញត្តិស្តីពីពន្ធប្រថាប់ត្រាជាធរមាន។

ឧទាហរណ៍ទី៤៖

បរធនបាលទាយក បានប្រគល់ប្រាក់ចំនួន ៧០០ លានរៀល ទៅឱ្យក្រុមហ៊ុនបរធនបាលដើម្បីគ្រប់គ្រង និងចាត់ចែង។ ក្រុមហ៊ុនបរធនបាល បានយកប្រាក់នេះទៅទិញដីមួយកន្លែងពីបុគ្គលផ្សេងទៀត ដោយដាក់ឈ្មោះក្រុមហ៊ុនបរធនបាលជាកម្មសិទ្ធិករ។ ក្នុងករណីនេះ ក្រុមហ៊ុនបរធនបាល គឺជាអ្នកទិញដែលត្រូវទទួលបន្ទុកក្នុងការបង់ពន្ធប្រថាប់ត្រា ដូចខាងក្រោម៖

ពន្ធប្រថាប់ត្រា = តម្លៃដី x អត្រាពន្ធ
= ៧០០ លានរៀល x ៤%
= ២៨ លានរៀល។

៤- ពន្ធកាត់ទុក៖

ក- ការបង្វែរប្រាក់ចំណូលក្រោយបង់ពន្ធឱ្យទៅអ្នកជាប់ពន្ធអនិវាសនជន គឺជាកម្មវត្ថុនៃពន្ធកាត់ទុក។ ប៉ុន្តែ ក្នុងករណីដែលប្រាក់ចំណូលនោះបានបង់ពន្ធលើចំណេញមូលធនរួចហើយ គឺមិនមែនជាកម្មវត្ថុនៃពន្ធកាត់ទុកទៀតទេ។

ខ- បរធនបាលជាអ្នកគ្រប់គ្រង និងចាត់ចែងបរធនបាលកិច្ច ត្រូវមានកាតព្វកិច្ចកត់ត្រាប្រតិបត្តិការក្នុងបញ្ជីគណនេយ្យរបស់ប្រតិបត្តិការបរធនបាលកិច្ច ដោយត្រូវគណនាពន្ធកាត់ទុក និងត្រូវដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធជូនរដ្ឋបាលសារពើពន្ធ ស្របតាមបទប្បញ្ញត្តិស្តីពីពន្ធកាត់ទុកជាធរមាន។

ឧទាហរណ៍ទី៥៖

បរធនបាលទាយកជាអនិវាសនជន បានប្រគល់ប្រាក់ទៅឱ្យក្រុមហ៊ុនបរធនបាលចំនួន ៤០០ លានរៀល ដើម្បីទិញផ្ទះមួយកន្លែងដោយដាក់ឈ្មោះក្រុមហ៊ុនបរធនបាលជាកម្មសិទ្ធិករ។ ក្រោយមកក្រុមហ៊ុនបរធនបាលបានលក់ផ្ទះនេះក្នុងតម្លៃ ៦០០ លានរៀល និងបានបង់ពន្ធលើចំណេញមូលធន ចំនួន ២៤ លានរៀល ដោយផលចំណេញត្រូវផ្ទេរទៅឱ្យបរធនបាលទាយកវិញ។

ផលចំណេញពីការលក់ផ្ទះ = ថ្លៃលក់ - ថ្លៃទិញ - ប្រាក់ពន្ធលើចំណេញមូលធន
= ៦០០ - ៤០០ - ២៤
= ១៧៦ លានរៀល។

ក្រុមហ៊ុនបរធនបាលដែលបានផ្ទេរផលចំណេញទៅបរធនបាលទាយកជាអនិវាសនជន មិនត្រូវអនុវត្តពន្ធកាត់ទុកតាមអត្រា ១៤% ទៅលើផលចំណេញពីការលក់ចំនួន ១៧៦ លានរៀល ទៀតទេ។

ប្រការ៩ .-

ក្រៅពីកាតព្វកិច្ចសារពើពន្ធដូចមានចែងក្នុងប្រការ៧ និងប្រការ៨ នៃប្រកាសនេះ បរធនបាលជាអ្នកគ្រប់គ្រង ចាត់ចែង និងថែរក្សាបរធន ត្រូវមានកាតព្វកិច្ចបង់ពន្ធអាករដទៃទៀត ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារជាធរមាន។

ប្រការ១០ .-

បទប្បញ្ញត្តិស្តីពីការលើកលែងពន្ធអាករដែលមានចែងចំពោះប្រភេទពន្ធអាករណាមួយ ត្រូវអនុវត្តផងដែរចំពោះទ្រព្យសម្បត្តិបរធនបាលកិច្ចដែលពាក់ព័ន្ធនឹងប្រភេទពន្ធអាករនោះ។

ប្រការ១១ .-

បរធនបាលត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធតាមការកំណត់របស់រដ្ឋបាលសារពើពន្ធ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារជាធរមាន។

ប្រការ១២ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ១៣ .-

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ឬអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១៤ កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០២៥

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

កន្លែងទទួល៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ [illegible]......សហវ.ប្រក

ប្រកាស
ស្ដីពី
ការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំ
នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៩២ ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ ២០២៣ ស្ដីពីការតែងតាំងរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២៥/៣៧៨ ចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ ២០២៥ ស្ដីពីការតែងតាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៥៨៨ សហវ.ប្រ ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០២៤ ស្ដីពីការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia

ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

ប្រការ ១.- ត្រូវបានបែងចែកភារកិច្ច ជូនថ្នាក់ដឹកនាំក្រសួង ដូចខាងក្រោម៖

ក. រដ្ឋលេខាធិការប្រចាំការ និង រដ្ឋលេខាធិការ

I. ឯកឧត្តមបណ្ឌិតសភាចារ្យ **ជូ ទិជិត្ត** រដ្ឋលេខាធិការប្រចាំការ ជួយប្រធានស្ថាប័ន ក្នុងក្របខណ្ឌការងារ ដូចខាងក្រោមៈ

១-គោលនយោបាយៈ សម្របសម្រួលការរៀបចំ, ការតាមដាន និងការវាយតម្លៃលើការអនុវត្តគោល-នយោបាយចំណូលថវិការដ្ឋ និងគោលនយោបាយលទ្ធកម្មសាធារណៈ ។

២-ជំនាញបច្ចេកទេសៈ គ្រប់គ្រងការងាររបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ និងសម្របសម្រួលការងារប្រមូលចំណូលមិនមែនសារពើពន្ធនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ។

៣ ការគ្រប់គ្រងក្រសួង ស្ថាប័ន ក្នុងឋានៈជាអភិបាលហិរញ្ញវត្ថុៈ គ្រប់គ្រងការងារចំណាយ, ការងារប្រមូលចំណូល និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៃក្រសួងមហាផ្ទៃ ។

៤-ការងារដោយឡែកៈ ជួយពិនិត្យ និងផ្តល់យោបល់ជូនប្រធានស្ថាប័ន លើការងារពាក់ព័ន្ធនឹងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, អគ្គនាយកដ្ឋានពន្ធដារ, គ្រឹះស្ថានអង្គរ, ជួយលើការប្រមូលចំណូលមិនមែនសារពើពន្ធក្នុងផ្នែកទិដ្ឋាការ និងជួយកិច្ចការផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

II. ឯកឧត្តម **ហ៊ីង សុទណ្ណា** រដ្ឋលេខាធិការ ជួយប្រធានស្ថាប័ន ក្នុងក្របខណ្ឌការងារដូចខាងក្រោមៈ

១- គោលនយោបាយ និងជំនាញបច្ចេកទេសៈ ជួយរដ្ឋលេខាធិការប្រចាំការ សម្របសម្រួលការរៀបចំ, ការតាមដាន និងការវាយតម្លៃលើការអនុវត្តគោលនយោបាយលទ្ធកម្មសាធារណៈ ក្រោមការដឹកនាំរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋលេខាធិការប្រចាំការ ដូចខាងក្រោម៖

- ជួយកិច្ចការកែទម្រង់លទ្ធកម្មសាធារណៈ, ជាពិសេស ពាក់ព័ន្ធនឹងការរៀបចំ និងការអនុវត្តលទ្ធកម្មប្រកបដោយចីរភាព និងលទ្ធកម្មតាមប្រព័ន្ធអេឡិចត្រូនិក;
- ជួយសម្របសម្រួលដោះស្រាយការងារបច្ចេកទេសលទ្ធកម្មសាធារណៈ ក្នុងនាមឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋលេខាធិការប្រចាំការ តាមការប្រគល់សិទ្ធិ;
- ជួយពិនិត្យ និងផ្តល់យោបល់លើការងារបច្ចេកទេសលទ្ធកម្មសាធារណៈ នៃសហគ្រាសសាធា-រណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ជូនថ្នាក់ដឹកនាំ តាមការប្រគល់សិទ្ធិរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋលេខាធិការប្រចាំការ;
- ពិនិត្យ និងសម្រេចលើការងារបច្ចេកទេសលទ្ធកម្មសាធារណៈ ក្នុងនាមឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋលេខាធិការប្រចាំការ តាមការប្រគល់សិទ្ធិ ។

២- ការគ្រប់គ្រងក្រសួង ស្ថាប័ន ក្នុងឋានៈជាអភិបាលហិរញ្ញវត្ថុៈ គ្រប់គ្រងការងារចំណាយ, ការងារប្រមូលចំណូល និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៃក្រសួងការពារជាតិ ។

៣-គ្រប់គ្រងការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តៈ គ្រប់គ្រងការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តស្ទឹងត្រែង ។
៤-ការងារដោយឡែកៈ ជួយការងារអតីតយុទ្ធជន និងជួយកិច្ចការដទៃទៀតតាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

III. ឯកឧត្តម **ឈឹម សារ៉េត** រដ្ឋលេខាធិការ ជួយប្រធានស្ថាប័ន ក្នុងក្របខណ្ឌការងារដូចខាងក្រោមៈ

១- គោលនយោបាយ និងជំនាញបច្ចេកទេសៈ ជួយរដ្ឋលេខាធិការប្រចាំការ សម្របសម្រួលការរៀបចំ, ការតាមដាន និងការវាយតម្លៃលើការអនុវត្តគោលនយោបាយលទ្ធកម្មសាធារណៈ ក្រោមការដឹកនាំរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋលេខាធិការប្រចាំការ ដូចខាងក្រោម៖

- ជួយកិច្ចការកែទម្រង់លទ្ធកម្មសាធារណៈ, ជាពិសេស ពាក់ព័ន្ធនឹងការរៀបចំ និងការជំរុញការអនុវត្តលិខិតបទដ្ឋានគតិយុត្ត ស្តីពីលទ្ធកម្មសាធារណៈ;
- ជួយសម្របសម្រួលដោះស្រាយការងារបច្ចេកទេសលទ្ធកម្មសាធារណៈ ក្នុងនាមឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋលេខាធិការប្រចាំការ តាមការប្រគល់សិទ្ធិ;
- ជួយពិនិត្យ និងផ្តល់យោបល់លើការងារបច្ចេកទេសលទ្ធកម្មសាធារណៈ នៃរដ្ឋបាលថ្នាក់ក្រោមជាតិ ជូនថ្នាក់ដឹកនាំ តាមការប្រគល់សិទ្ធិរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋលេខាធិការប្រចាំការ,
- ពិនិត្យ និងសម្រេចលើការងារបច្ចេកទេសលទ្ធកម្មសាធារណៈ ក្នុងនាមឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋលេខាធិការប្រចាំការ តាមការប្រគល់សិទ្ធិ;

២-ការងារដោយឡែកៈ ជួយកិច្ចការដទៃទៀតតាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

ខ. អនុរដ្ឋលេខាធិការ

I. ឯកឧត្តម **ឡុង ជិនរិទ្ធ** អនុរដ្ឋលេខាធិការ ជួយប្រធានស្ថាប័ន ក្នុងក្របខណ្ឌការងារដូចខាងក្រោមៈ

១- ជំនាញបច្ចេកទេសៈ ជួយឯកឧត្តមរដ្ឋលេខាធិការប្រចាំការ សម្របសម្រួលការរៀបចំ, ការតាមដាន និងការវាយតម្លៃលើការអនុវត្តគោលនយោបាយលទ្ធកម្មសាធារណៈ, ជាពិសេស ពាក់ព័ន្ធនឹងការពង្រឹងយន្តការត្រួតពិនិត្យកិច្ចលទ្ធកម្មតាមក្រោយ និងការងារដទៃទៀត តាមការប្រគល់សិទ្ធិ ។
២- ការគ្រប់គ្រងក្រសួង-ស្ថាប័ន ក្នុងឋានៈជាអភិបាលហិរញ្ញវត្ថុៈ គ្រប់គ្រងការងារចំណាយ, ការងារប្រមូលចំណូល និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។
៣- ការងារដោយឡែកៈ ជួយកិច្ចការដទៃទៀតតាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

II. ឯកឧត្តម **ហោ ច័ន្ទតារ៉ាវុធី** អនុរដ្ឋលេខាធិការ ជួយប្រធានស្ថាប័ន ក្នុងក្របខណ្ឌការងារដូចខាងក្រោមៈ

១- ទទួលបន្ទុកជានាយករងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
២- ការងារដោយឡែកៈ ជួយកិច្ចការដទៃទៀតតាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

III. ឯកឧត្តម **ពៅ រិទ្ធជ័យសិទ្ធ** អនុរដ្ឋលេខាធិការ ជួយប្រធានស្ថាប័ន ក្នុងក្របខណ្ឌការងារដូចខាងក្រោមៈ

១- ជំនាញបច្ចេកទេសៈ ជួយរដ្ឋលេខាធិការទទួលបន្ទុកគោលនយោបាយអភិវឌ្ឍវិស័យឯកជន ។

២- ការងារដោយឡែកៈ ជួយរដ្ឋលេខាធិការ លើការងារក្រុម «ឃ», ការងារពាក់ព័ន្ធអង្គការពាណិជ្ជកម្មពិភពលោក (WTO), ការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រ ផែនការអភិវឌ្ឍ និងគោលនយោបាយនានា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជួយកិច្ចការដទៃទៀតតាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

ប្រការ ២.- - ចំពោះការឆ្លងឯកសារប្រចាំថ្ងៃ, អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ ដាក់ឯកសារចរន្តប្រចាំថ្ងៃ ឆ្លងរដ្ឋលេខាធិការទទួលបន្ទុកគោលនយោបាយ និងបច្ចេកទេស តាមការប្រគល់សិទ្ធិ, ឆ្លងរដ្ឋលេខាធិ-ការប្រចាំការ រួចបញ្ជូនឯកសារមកសុំការពិនិត្យសម្រេចរបស់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ដោយឡែក, ចំពោះការចាត់តាំងបុគ្គលិក, អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈត្រូវបញ្ជូនសំណើ ឆ្លងការពិនិត្យ និងផ្តល់យោបល់ ពីរដ្ឋលេខាធិការប្រចាំការ ដែលទទួលបន្ទុកអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ រួចបញ្ជូនត្រង់មកសុំការពិនិត្យសម្រេចរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- ចំពោះភារកិច្ច, សិទ្ធិអំណាច, នីតិវិធី, របៀបរបបបំពេញការងារប្រចាំថ្ងៃ និងរបបប្រជុំ, ត្រូវអនុលោមតាមប្រកាសលេខ ៥៨៨ សហវ.ប្រ ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០២៤ ស្តីពីការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ប្រការ ៣.- រដ្ឋលេខាធិការប្រចាំការ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គាធិការ អគ្គនាយក នាយកវិទ្យាស្ថាន និងគ្រប់ប្រធានអង្គភាព ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃចន្ទ ៦រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែមីនា គ.ស ២០២៥

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

<u>កន្លែងទទួលៈ</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ដូចប្រការ ៣ «ដើម្បីអនុវត្ត»
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០៧ សហវ.ប្រក.អយក

ប្រកាសអន្តរក្រសួង
ស្តីពី
ការតែងតាំងវេជ្ជបណ្ឌិតប្រចាំការ និងវេជ្ជបណ្ឌិតប្រចាំការរង ប្រចាំនៅអង្គភាពលទ្ធកម្មអគ្គលេខាធិការដ្ឋាន នៃក្រសួងអប់រំ យុវជន និងកីឡា

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្ម មាត្រា៩ និងមាត្រា១០នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៩/១១ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្ម មាត្រា៥១ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ១០១ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ
- ប្រកាសអន្តរក្រសួងលេខ៧៧៧ សហវ.ប្រក.អថ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការដាក់ឱ្យអនុវត្តអង្គភាពថវិកា
- បានឃើញប្រកាសលេខ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ៦៦៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពថវិកាអគ្គលេខាធិការដ្ឋាន នៃក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

ប្រការ១ ._

ត្រូវបានតែងតាំងមន្ត្រីរាជការរបស់**អង្គភាពថវិកាអគ្គលេខាធិការដ្ឋាន ជាអាណាប័កផ្ទេរសិទ្ធិពេញលេញ** នៃក្រសួងអប់រំ យុវជន និងកីឡា ដូចខាងក្រោម៖

១.លោក **សេង ចាន់សុវណ្ណារ៉ុ** មុខងារជាអនុប្រធាននាយកដ្ឋាន ជារដ្ឋទេយ្យករបុរេប្រទាន នៅអគ្គលេខាធិការដ្ឋាន នៃក្រសួងអប់រំ យុវជន និងកីឡា

២.លោក **ព្រុំ ដារ៉ា** មុខងារជាអនុប្រធាននាយកដ្ឋាន ជារដ្ឋទេយ្យករបុរេប្រទានរងនៅអគ្គលេខាធិការដ្ឋាន នៃក្រសួងអប់រំ យុវជន និងកីឡា

៣.លោកស្រី **ពៅ ចន្ធូ** មុខងារជាអនុប្រធាននាយកដ្ឋាន ជារដ្ឋទេយ្យករបុរេប្រទានរង នៅអគ្គលេខាធិការដ្ឋាន នៃក្រសួងអប់រំ យុវជន និងកីឡា

៤.លោក **ជាវង់ សុខរិទ្ធ** មុខងារជាប្រធានការិយាល័យ ជារដ្ឋទេយ្យករបុរេប្រទានរង នៅអគ្គលេខាធិការដ្ឋាន នៃក្រសួងអប់រំ យុវជន និងកីឡា

៥.លោក **ជុំ សាម** មុខងារជាប្រធានការិយាល័យ ជារដ្ឋទេយ្យករបុរេប្រទានរង នៅអគ្គលេខាធិការដ្ឋាន នៃក្រសួងអប់រំ យុវជន និងកីឡា

៦.លោក **អ៊ុង សាមិត្ត** មុខងារជាប្រធានការិយាល័យ ជារដ្ឋទេយ្យករបុរេប្រទានរង នៅអគ្គលេខាធិការដ្ឋាន នៃក្រសួងអប់រំ យុវជន និងកីឡា

៧.លោកស្រី **កែវ ចន្ធូ** មុខងារជាប្រធានការិយាល័យ ជារដ្ឋទេយ្យករបុរេប្រទានរង នៅអគ្គលេខាធិការដ្ឋាន នៃក្រសួងអប់រំ យុវជន និងកីឡា

៨.លោក **ទ្រិញ តុង** មុខងារជាអនុប្រធានការិយាល័យ ជារដ្ឋទេយ្យករបុរេប្រទានរង នៅអគ្គលេខាធិការដ្ឋាន នៃក្រសួងអប់រំ យុវជន និងកីឡា

៩.លោក **ខៀវ មាន** មុខងារជាអនុប្រធានការិយាល័យ ជារដ្ឋទេយ្យករបុរេប្រទានរងនៅអគ្គលេខាធិការដ្ឋាន នៃក្រសួងអប់រំ យុវជន និងកីឡា

១០.លោកស្រី **ជាតិ រតនៈវតី** មុខងារជាអនុប្រធានការិយាល័យ ជារដ្ឋទេយ្យករបុរេប្រទានរងនៅអគ្គលេខាធិការដ្ឋាន នៃក្រសួងអប់រំ យុវជន និងកីឡា

១១.លោក **ឋោង ពៅ** មុខងារជាអនុប្រធានការិយាល័យ ជារដ្ឋទេយ្យករបុរេប្រទានរង នៅអគ្គលេខាធិការដ្ឋាន នៃក្រសួងអប់រំ យុវជន និងកីឡា

១២.កញ្ញា **សឿង ចាន់ថូ** មុខងារជាអនុប្រធានការិយាល័យ ជារដ្ឋទេយ្យករបុរេប្រទានរង នៅអគ្គលេខាធិការដ្ឋាន នៃក្រសួងអប់រំ យុវជន និងកីឡា

១៣.កញ្ញា **យឹម សុវណ្ណាលក្សណ៍** មុខងារជាអនុប្រធានការិយាល័យ ជារដ្ឋទេយ្យករបុរេប្រទានរង នៅអគ្គលេខាធិការដ្ឋាន នៃក្រសួងអប់រំ យុវជន និងកីឡា។

ប្រការ២ ._

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៣ ._

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងអគ្គលេខាធិការដ្ឋាន នៃក្រសួងអប់រំ យុវជន និងកីឡា ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១០កើត ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ មករា ឆ្នាំ២០២៥

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

កន្លែងទទួល

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ក្រសួងអប់រំ យុវជន និងកីឡា
- ខុទ្ទកាល័យ សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៣៦ ... សហវ.ប្រក

ប្រកាសអន្តរក្រសួង
ស្តីពី
ការតែងតាំងរដ្ឋលេខាធិការ ប្រចាំការ នៅអង្គភាពថវិកាអគ្គនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ជាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញនៃក្រសួងអប់រំ យុវជន និងកីឡា

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia

ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៩/១១ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៥១នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១០១ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ៦៦៣ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ
